# ការបង្កើនលទ្ធភាពក្នុងការទទួលបានការរំលូតកូនដោយសុវត្ថិភាព

## គម្រោងសុខភាពស្ត្រីនៅក្នុងប្រទេសកម្ពុជា



## សេចក្ដីផ្ដើម

ទូទាំងសកលលោកការរំលូតកូនដោយគ្មានសុវត្ថិភាព បណ្ដាលឲ្យមានអត្រាមរណៈភាពរបស់មាតា រហូតដល់ ១៣%។ នៅក្នុងឆ្នាំ ២000 អត្រាមរណៈភាពរបស់មាតាក្នុងប្រទេសកម្ពុជាស្ថិតនៅខ្ពស់ជាងគេនៅក្នុងតំបន់ ដោយមានអ្នកស្លាប់ចំនួន ៤៣៧នាក់ ក្នុងចំនោម ១00,000នាក់ នៃកំណើតរស់ អត្រាមរណៈភាពនេះ មានជាប់ពាក់ព័ន្ធជាមួយនឹងផលវិបាកការរំលូតកូនដោយគ្មានសុវត្ថិភាព ជំងឺក្រឡាភ្លើង និងការធ្លាក់ឈាម[2] ថ្វីបើការរំលូតកូនត្រូវបានប្រកាសថាជាទង្វើស្របច្បាប់នៅក្នុងឆ្នាំ ១៩៩៧ ហើយក៏ដោយមានស្ត្រីជាច្រើន នៅតែមិនអាចទទួលសេវាការរំលូតកូនដោយសុវត្ថិភាពដដែល។ ដោយសារតែតម្លៃថ្លៃពេក សេវានៃការរំលូតកូន គ្មានគុណភាព កង្វះឧបករណ៍ និងការប្រើប្រាស់ថ្នាំមិនត្រឹមត្រូវ និងគ្មានគុណភាព។[4] ចាប់តាំងពីពេលនោះមក ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងអ្នកជាប់ពាក់ព័ន្ធសំខាន់ៗផ្សេងទៀត បានដំណើរការដ៏គួរអោយកត់សម្គាល់ក្នុងការបង្កើនលទ្ធភាព ក្នុងការទទួលបានការរំលូតកូនដោយសុវត្ថិភាព ជាលទ្ធផលនៅដើមឆ្នាំ ២០១៤ អត្រានៃការស្លាប់របស់មាតា ចុះមកត្រឹម ១៧0នាក់ ក្នុងចំណោម ១00,000នាក់ ន កំណើតរស់។[5]

## សមិទ្ធផលសំខាន់

| | | |
|---|---|---|
| ថ្នាំរំលូតជាង២លានកញ្ចប់ត្រូវបានចែកចាយតាំងពីឆ្នាំ ២00៩ | ជាង ២,៨00 ទីតាំង មានលក់ថ្នាំរំលូតកូនរបស់អង្គការ ភី អេស អាយ ចាប់ពីឆ្នាំ ២០១៩ | ស្ត្រីជាង ១៤,000នាក់ ត្រូវបញ្ជូនទៅរកសេវារំលូត ដែលមានសុវត្ថិភាពតាមរយៈភ្នាក់ងារអប់រំផ្សព្វផ្សាយ ចាប់ពីឆ្នាំ ២០១៧ |
| ស្ត្រីក្រោយរំលូតជាង ៥,000នាក់ ត្រូវបានបញ្ជូលទៅសេវាថែទាំ ក្រោយរំលូតដោយភ្នាក់ងារអប់រំផ្សព្វផ្សាយ ចាប់ពីឆ្នាំ ២០១៤មក | បណ្ដាញផ្ដល់សេវា និងមិនមែនបណ្ដាញចំនួនជាង ២៥00នាក់ ត្រូវបានបណ្ដុះបណ្ដាលស្ដីពីជម្រើសនៃការមានផ្ទៃពោះ ចាប់ពីឆ្នាំ២00៨ | អ្នកផ្ដល់សេវា និងឱសថការីជាង ៥៩00នាក់បានទទួលនូវការគាំទ្រ អន្តរគមន៍ពីក្រុមការងារ PBCC យ៉ាងហោចណាស់មួយដងដែរ ចាប់ពីខែកក្កដាឆ្នាំ ២០១០មក។ |

[1] World Health Organization. (2011). "Unsafe abortion: global and regional estimates of the incidence of unsafe abortion and associated mortality in 2008: Sixth edition".
[2] "Cambodian Demographic Health Survey". (2000). National Institute of Statistics, Directorate General for Health, and ICF International. Cambodia.
[3] Rathavy, Tung, Tamara Fetters, Jill Sherman, Sophonn Vonthanak, Saray Vannat, Lam Phirun and Thou Chourn. (2007). "Ready or not? A National needs assessment of abortion services in Cambodia." Ipas.
[4] PSI/Cambodia. (2009). "Current Practice of Medical Abortion, Quick Survey". Cambodia.
[5] "Cambodian Demographic Health Survey" (CDHS). (2014). National Institute of Statistics, Directorate General for Health, and ICF International. Cambodia.

50 psi FORWARD

# គម្រោងសុខភាពរបស់ស្ត្រី

គម្រោងសុខភាពស្ត្រីត្រូវបានអនុវត្តឡើងតាមរយៈ អង្គការ ភី អេស អាយ នៅចន្លោះឆ្នាំ ២០០៨-២០២០ ដែលដើរតួយ៉ាងសំខាន់ក្នុងការបង្កើតស្ថេរភាពទីផ្សារថ្នាំរំលូតកូន និងបង្កើនការទទួលបានការរំលូតកូនដោយសុវត្ថិភាព និងការពន្យារកំណើតបន្ទាប់ពីការរំលូតកូននៅក្នុងប្រទេសកម្ពុជា។

## ពង្រីកការចែកចាយថ្នាំរំលូតកូនដែលបានចុះបញ្ជី

នៅក្នុងឆ្នាំ ២០០៩ ការសិក្សាស្រាវជ្រាវរបស់អង្គការ ភី អេស អាយ បានបង្ហាញថា ថ្នាំរំលូតកូនជាង ៨៧% ត្រូវបានដាក់លក់នៅលើទីផ្សារកម្ពុជា ហើយភាគច្រើនគឺត្រូវបានផលិតនៅប្រទេសចិន ដោយមានកញ្ចប់ និងការណែនាំជាភាសាចិន ហើយក្នុងនោះមានថ្នាំចំនួន ១៩% គ្មានសារធាតុផ្សំបានត្រឹមត្រូវក្នុងការរំលូតកូន។[6]

អង្គការ ភី អេស អាយ បានធ្វើការចុះឈ្មោះថ្នាំរំលូតកូនមេដាបូនដំបូងគេបង្អស់នៅក្នុងឆ្នាំ ២០០៩ និងចាប់ផ្តើមចែកចាយទូទាំងប្រទេសនៅឆ្នាំបន្តបន្ទាប់នៅក្រោមគម្រោងសុខភាពស្ត្រីអង្គការ ភី អេស អាយ បានចែកចាយថ្នាំរំលូតកូនជាង ២,១០៦,០០០ កញ្ចប់រួមបញ្ចូលទាំង ៥២,៧១០ ទៅក្នុងក្រសួងសុខាភិបាល (តារាងទី1)។ ការចែកចាយនេះរួមបញ្ចូលទាំងថ្នាំមេដាបូន និងមាយហ្វេសូ ដែលជាផលិតផលទីពីររបស់អង្គការ ភី អេស អាយ ដែលបានដាក់អោយដំណើរការនៅក្នុងឆ្នាំ២០១៨។ នៅខែធ្នូ ឆ្នាំ ២០១៩, បានចែកចាយដល់កន្លែងលក់ថ្នាំចំនួន ២,៨៨៤ ទីតាំងទូទាំង ៩៤% នៃស្រុកក្នុងប្រទេសកម្ពុជា។ ការពង្រីកការចែកចាយថ្នាំរំលូតកូនដោយសុវត្ថិភាព គុណភាព និងបានចុះបញ្ជីទៅក្នុងទីផ្សារ បានកាត់បន្ថយការប្រើប្រាស់ថ្នាំរំលូតកូនគ្មានសុវត្ថិភាព ដែលបានផលិតនៅប្រទេសចិន និងមានការណែនាំប្រើប្រាស់ជាភាសាចិនគួរអោយកត់សម្គាល់ ដែលបានកាត់បន្ថយពី ២% នៅក្នុងឆ្នាំ ២០១៣ រហូតដល់សូន្យភាគរយ នៅក្នុងឆ្នាំ ២០១៨។(តារាងទី 2៖)[7]

[6]PSI/Cambodia. (2009). "Current Practice of Medical Abortion, Quick Survey". Cambodia.
[7]PSI/Cambodia. (2018). "RH Distribution Survey: Third Round". Cambodia.
[8]Cost of goods sold: All direct costs attributable to the production of goods sold, including the cost of production, packaging, and all fees associated with shipping and handling.
[9]PSI/Cambodia. (2017). "RH Tracking Results Continuously among Women of Reproductive Age". Cambodia.

GRAPH 1. PSI/C MA DISTRIBUTION




GRAPH 2. AVAILABILITY OF MA BY BRAND




### ការបង្កើតនិរន្តរភាពទីផ្សារសម្រាប់ថ្នាំរំលូតកូន

ក្នុងអំឡុងពេលដែលនិន្នាការជំនួយផលិតផលសុខភាពត្រូវបានផ្លាស់ប្តូរ ការបង្កើតទីផ្សារដែលមាននិរន្តរភាពគឺពិតជាចាំបាច់ក្នុងការបន្តធានានូវលទ្ធភាពក្នុងការទទួលបានផលិតផលសុខភាពដែលចាំបាច់។ នៅឆ្នាំ២០១០ អង្គការ ភី អេស អាយ បានចាប់ផ្តើមថ្នាំមេដាបូន លក់ក្នុងតម្លៃជំនួយឧបត្ថម្ភដែលធានាដល់ប្រាក់ចំនេញអ្នកបោះដុំ បើធៀបជាមួយនិងថ្នាំរំលូតកូនផ្សេងទៀតដែលមិនបានចុះបញ្ជី និងមានគុណភាពទាបនៅលើទីផ្សារ។ ចាប់តាំងពីពេលនោះមក ថ្នាំមេដាបូន ទទួលបានកំណើននៃការលក់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយតម្លៃក៏មានការកើនឡើងផងដែរ ព្រមទាំងទទួលបានថ្លៃដើមនៅក្នុងឆ្នាំ[8] ២០១៦។ នៅឆ្នាំ២០១៧ ប្រមាណជាពីភាគបី (៦៤%) នៃស្ត្រីដែលរំលូតកូនបានប្រើថ្នាំរំលូតកូន និងហើយក្នុងនោះមាន ៧៤% បានប្រើប្រាស់ថ្នាំមេដាបូន[9]។ នៅឆ្នាំ ២០២០ ទាំងផលិតផលម៉ាយហ្វេសូ និង មេដាបូនត្រូវបានបញ្ចូលទៅក្នុងមូលនិធិសហគ្រាស ដែលជាសហគ្រាសសង្គមរបស់អង្គការ ភី អេស អាយ ក្នុងគោលបំណងស្វែងរកប្រាក់ចំនេញ ដើម្បីបង្កើតស្ថេរភាពក្នុងការផ្គត់ផ្គង់ផលិតផល និងដើម្បីរក្សាផលប៉ះពាល់និរន្តរភាពសុខភាពផងដែរ។ ក្នុងនាមជា ផលិតផលមួយរបស់មូលនិធិសហគ្រាស ផលិតផលទាំងពីរនេះ នឹងបន្តផ្តល់ជូនស្ត្រីទូទាំងកម្ពុជាបន្ទាប់ពីគម្រោងត្រូវបានបញ្ចប់។

# ការបង្កើតលទ្ធភាពក្នុងការទទួលបានព័ត៌មាន និងសេវាតាមរយៈការផ្លាស់ប្តូរឥរិយាបថនៃការប្រាស្រ័យទាក់ទងសង្គម

ការផ្លាស់ប្តូរឥរិយាបថនៃការប្រាស្រ័យទាក់ទងសង្គម គឺពិតជាចាំបាច់ក្នុងបង្កើនលទ្ធភាពក្នុងការទទួលបានព័ត៌មានអំពីការរំលូតកូនដោយសុវត្ថិភាព និងណែនាំស្ត្រីទៅកាន់សេវាដែលពួកគេត្រូវការ។

## បច្ចេកវិទ្យាឌីជីថល

បណ្តាញទូរស័ព្ទសុខភាពស្ត្រីៈ ចាប់តាំងពីឆ្នាំ ២០១៣ មក បណ្តាញទូរស័ព្ទនេះបានទទួលការហៅចូលប្រមាណ ១០៧,៤៤០ដង ដែលក្នុងនោះមានប្រមាណ ៤៧,៨៣០ ដង ដែលទាក់ទងនិងការរំលូតកូន។ លើសពីនេះ ចាប់តាំងពីឆ្នាំ២០១៦មក បណ្តាញទូរស័ព្ទសុខភាពស្ត្រីបានធ្វើការណែនាំស្ត្រីជាង ៧,៨៥០ អោយទទួលយកការពន្យារកំណើតបន្ទាប់ពីការរំលូតកូន។

ការហៅទៅលេខ 3-2-1៖ នៅក្នុងឆ្នាំ ២០១៦ អង្គការ ភី អេស អាយ បានបង្កើតសារជាសម្លេងក្នុងការតបសម្លេងដោយស្វ័យប្រវត្តិ Viamo ការហៅទៅលេខ 3-2-1 ដើម្បីបង្កើនលទ្ធភាពក្នុងការទទួលបានព័ត៌មានទាក់ទងនិងការរំលូតកូនដោយសុវត្ថិភាព និងការពន្យារកំណើត។ នៅខែកក្កដា ឆ្នាំ២០២០ ការហៅទៅលេខ 3-2-1 បានទទួលការហៅចូលជាង ១៣,១៣០ដង។

ទំព័រយុវវ័យហ្វេសប៊ុក៖ សម្តស្សបញ្ញា បានទទួលការចូលចិត្តចំនួន២០,០០០ និងមានអ្នកតាមដានជាង ២១,០០០អ្នក។

សាច់រឿងជាសម្លេង៖ អង្គការ ភី អេស អាយ បានបង្កើតសាច់រឿងជាសម្លេង ១៦វគ្គ ដែលមានឈ្មោះថា "បងប្អូនស្រីពីរនាក់ក្តីសុបិន្តមួយ និងការលាក់ទុកការសម្ងាត់" និងបានចាក់ផ្សាយតាមបណ្តាញផ្សព្វផ្សាយការហៅទៅលេខ 3-2-1 និងបណ្តាញសង្គមនានា។ ចាប់តាំងពីសាច់រឿងជាសម្លេងត្រូវបានចាក់ផ្សាយមក ការហៅទៅលេខ 3-2-1 នៅក្នុងឆ្នាំ២០១៩ មានការកើនឡើងគួរអោយកត់សម្គាល់ដោយអ្នកហៅចូលមានការកើនឡើងពី ៥៥៩ដង នៅក្នុងឆ្នាំ២០១៨ ដល់ជាង ៨,០០០ដងនៅក្នុងឆ្នាំ ២០១៩។

## ការបង្កើនលទ្ធភាពក្នុងការទទួលបានការពន្យារកំណើតបន្ទាប់ពីការរំលូតកូនតាមរយៈកម្មវិធីទូរស័ព្ទ

ដើម្បីពង្រីកលទ្ធភាពក្នុងការទទួលបានការពន្យារកំណើតបន្ទាប់ពីការរំលូតកូន អង្គការ ភី អេស អាយ បានបង្កើតកម្មវិធីទូរស័ព្ទ និងដាក់ឲ្យសាកល្បងដើម្បីណែនាំអ្នកប្រើប្រាស់ដែលបានទិញថ្នាំរំលូតកូនពីកន្លែងលក់ថ្នាំ មកជួបអ្នកផ្តល់សេវាឯកជនដើម្បីធ្វើការតាមដាន និងផ្តល់ការប្រឹក្សាយោបល់អំពីការពន្យារកំណើត។ អ្នកប្រើប្រាស់ចំនួន ១,៦២១នាក់ បានចុះឈ្មោះនៅក្នុងកម្មវិធីទូរស័ព្ទ ដែលក្នុងនោះមាន ៧១% ដែលអ្នកផ្តល់សេវាអាចធ្វើការទាក់ទងបាន។ អ្នកដែលទទួលបានការតាមដានក្នុងនោះ ៦៤% បានទទួលការពន្យារកំណើតបន្ទាប់ពីការរំលូតកូនអ្នកបណ្តាញអ្នកផ្តល់សេវា(៨៨) ឬអ្នកផ្តល់សេវាមិនមែនជាបណ្តាញ (៦៥៣) ក្នុងរយៈពេល ១១ខែបន្ទាប់ពីរំលូតកូន។ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាដើម្បីភ្ជាប់បណ្តាញសុខភាពដែលមានស្រាប់កម្មវិធីទូរស័ព្ទជួយសម្រួលអោយអ្នកប្រើប្រាស់មានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានអំពីផលិតផល និងសេវាកម្មដែលពួកគេត្រូវការដើម្បីធ្វើការសម្រេចចិត្តលើការពន្យារកំណើត។

## ការប្រាស្រ័យទំនាក់ទំនងអន្តរបុគ្គល

តាមរយៈវិសាលភាពនៃគម្រោងសុខភាពស្ត្រីនៃ អង្គការ ភី អេស អាយ ប្រើប្រាស់គម្រូពីរក្នុងកម្មវិធីការប្រាស្រ័យទាក់ទងអន្តរបុគ្គល - ការអនុវត្តដោយផ្ទាល់តាមរយៈអ្នកអប់រំផ្សព្វផ្សាយតាមសហគមន៍ និងតាមរយៈភ្នាក់ងារផ្សព្វផ្សាយរបស់អង្គការក្នុងស្រុក តាមរយៈការផ្តល់ថវិកា សម្រាប់អង្គការទាំងនោះ។

ចាប់តាំងពីឆ្នាំ ២០១៧មក ស្ត្រីប្រមាណជាង១,៤៤០នាក់បានទទួលបាននូវទទួលយកសេវារំលូតកូនដោយសុវត្ថិភាពតាមរយៈការប្រាស្រ័យទាក់ទងជាមួយអ្នកអប់រំផ្សព្វផ្សាយ។ ភាគច្រើន(៨៤%)បានទទួលការណែនាំទៅកាន់បណ្តាញអ្នកផ្តល់សេវា ហើយ១៥%បានទទួលការណែនាំទៅកាន់កន្លែងផ្តល់សេវាសាធារណៈ។ អ្នកអប់រំផ្សព្វផ្សាយ សហគមន៍ និងភ្នាក់ងារអប់រំអន្តរបុគ្គលបានទាក់ទងដោយផ្ទាល់ក៏បានធ្វើការតាមដានស្ត្រីដែលទើបនឹងរំលូតកូនផងដែរដើម្បីផ្តល់ជំនួយ និងការប្រឹក្សាយោបល់ដល់ពួកគេទាក់ទងនឹងការត្រលប់មកវិញនូវបង្កកំណើត។

ចាប់តាំងពីឆ្នាំ ២០១៤ មកអ្នកផ្សព្វផ្សាយតាមសហគមន៍ និងភ្នាក់ងារប្រាស្រ័យទាក់ទងផ្ទាល់ខ្លួនបានជួយដល់ស្ត្រីទើបនឹងរំលូតកូនជាង ១៥,០០០នាក់ និងបានណែនាំជាង ៥,០០០នាក់អោយទទួលសេវាពន្យារកំណើតបន្ទាប់ពីការរំលូតកូន។

## ការចែកចាយ៖ ផលិតផលថ្នាំរំលូតកូននៅមណ្ឌលសុខភាព

ពង្រីកការចែកចាយផលិតផលថ្នាំរំលូតកូននៅកម្រិតមណ្ឌលសុខភាព គឺមានសក្តានុពលក្នុងការបង្កើនលទ្ធភាពទទួលបានការរំលូតកូនប្រកបដោយសុវត្ថិភាព ជាពិសេសសម្រាប់ស្រ្តីនៅតាមជនបទ។ ដើម្បីជាការជូនដំណឹងអំពីការដាក់បញ្ចូលសេវាកម្មថ្នាំរំលូតកូនទៅកាន់មណ្ឌលសុខភាព អង្គការ ភី អេស អាយ អង្គការម៉ារីស្តុប មូលនិធិដើមត្នោត និងសេវាសុខភាពគ្លីនតុនក្នុងការអនុវត្តគំនិតផ្តួចផ្តើមចែកចាយផលិតផលរំលូតដោយសុវត្ថិភាពនៅកម្រឹតមណ្ឌលសុខភាព។ លទ្ធផលនៃការចែកចាយកាន់តែបានបញ្ជាក់អោយកាន់តែច្បាស់ថែមទៀតនូវផលិតផលរំលូតដោយសុវត្ថិភាពនៅកម្រឹតមណ្ឌលសុខភាពកាន់តែមានសុវត្ថិភាព ប្រសិទ្ធិភាព ហើយអតិថិជនអាចទទួលបាននូវតម្លៃសមរម្យ។

តាមរយៈការពិនិត្យរបស់អង្គការទាំង៤

- ៩៨% នៃអ្នកប្រើប្រាស់ថ្នាំរំលូតកូន មានការរំលូតស្អាតអស់
- ភាគច្រើននៃស្រ្តី (ពី ៥១% ទៅ ៩០% អាស្រ័យលើគំរូសាកល្បងនិងគម្រោង) បានអនុវត្តវិធីសាស្រ្តទំនើបនៃផែនការគ្រួសារក្នុងរយៈពេលមួយខែបន្ទាប់ពីការរំលូតកូន។

## ធ្វើអោយប្រសើរឡើងនូវសេវាកម្មឯកជន

អង្គការ ភី អេស អាយ បានធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាតាមរយៈវិស័យឯកជនដោយមានវគ្គបណ្តុះបណ្តាលដល់អ្នកផ្តល់សេវាសុខភាពក្រៅបណ្តាញស្តីពីជម្រើសនៃការមានផ្ទៃពោះ និងផ្តល់ការគាំទ្រជាបន្តបន្ទាប់។

ក្រោមការគាំទ្រពីគម្រោងសុខភាពស្រ្តី

- បណ្តាញបន្ទប់ពិគ្រោះព្យាបាលសញ្ញាព្រះអាទិត្យជាង ២៥០នាក់បានទទួលនូវការបណ្តុះបណ្តាលស្តីពីជម្រើសនៃការមានផ្ទៃពោះ ហើយជាទូទៅក្នុងរយៈពេលមួយឆ្នាំ មានបុគ្គលិកចុះទៅពិនិត្យ៣ទៅ៤ដង។
- អ្នកផ្តល់សេវាជាង២,៥១០នាក់ រួមទាំងបណ្តាញបន្ទប់ពិគ្រោះព្យាបាលសញ្ញាព្រះអាទិត្យ និងមិនមែនជាបណ្តាញបានទទួលវគ្គបណ្តុះបណ្តាលស្តីពីជម្រើសនៃការមានផ្ទៃពោះចាប់ពីឆ្នាំ ២០០៨មក។
- អ្នកផ្តល់សេវា និងឱសថការីជាង ៥៩០០នាក់បានទទួលនូវការគាំទ្រអន្តរគមន៍ពីក្រុមការងារ PBCC យ៉ាងហោចណាស់មួយដងដែរចាប់ពីខែកក្កដា ឆ្នាំ ២០១០មក។

## សូមអរគុណ

គម្រោងសុខភាពស្រ្តី ត្រូវបានធ្វើឡើងតាមរយៈជំនួយសប្បុរស និងអ្នកជាប់ពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។ អង្គការ ភី អេស អាយ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរក្នុងស្រុកផ្សេងទៀតដែលបានសហការអស់រយៈពេលជាងមួយទសវត្ស និងបានបញ្ចប់ការសហការ។ អង្គការ ភី អេស អាយ ក៏សូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នានៅបន្ទប់ពិនិត្យពិគ្រោះព្យាលបាលសញ្ញាព្រះអាទិត្យដែលបានប្តេជ្ញាចិត្តក្នុងការផ្តល់សេវាប្រកបដោយគុណភាពខ្ពស់ និងធ្វើអោយប្រសើរឡើងនូវសុខភាពស្រ្តីកម្ពុជា។ ជាចុងក្រោយ ក៏សូមថ្លែងអំណរគុណដល់ក្រុមការងារ ភី អេស អាយ ទាំងមូលដែលបានជួយជ្រោមជ្រែងផ្នែកបច្ចេកទេសដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន។

### សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទាក់ទងមកកាន់

វេជ្ជ. ហេងខេង
នាយក សុខភាពបន្តពូជ និងផ្លូវភេទ
kheng@psi.org.kh

SHIRINE MOHAGHEGHPOUR
ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់សេវាកម្មដឹកជញ្ជូន
smohagheghpour@psi.org